ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

#

ថ្ងៃ ពុធ ១០ កើត ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងាររវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយ ឯកឧត្តម PABLO KANG ឯកអគ្គរាជទូតនៃប្រទេសអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

៙៙៙❈៚៚៚#

នាព្រឹកថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានអនុញ្ញាតឱ្យ **ឯកឧត្តម PABLO KANG** ឯកអគ្គរាជទូតនៃប្រទេសអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបពិភាក្សាការងារ តាមប្រព័ន្ធ Video Conference ។

ក្នុងជំនួបពិភាក្សានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវក្តីសោមនស្សរីករាយ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលអូស្ត្រាលី ដែលតែងតែបន្តផ្តល់ការគាំទ្រទាំងបច្ចេទេស និង ហិរញ្ញវត្ថុសម្រាប់កិច្ចអភិវឌ្ឍនៅកម្ពុជាស្ទើរលើគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម តាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជាជំហានទី ១ និង ២ (Cambodia Agricultural Value Chain Program) ដែលផ្តោតលើស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រកសិកម្ម, ការលើកកម្ពស់ពាណិជ្ជនីយកម្មកសិកម្ម និង ភាពធន់កសិកម្ម ជាដើម ។

ក្នុងឱកាសនោះ, **ឯកឧត្តម PABLO KANG ឯកអគ្គរាជទូតអូស្ត្រាលី** បានជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** នូវវឌ្ឍនភាពនៃគម្រោងនានាដែលទទួលបានការគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី ដូចជា៖ គំនិតផ្តួចផ្តើមភាពជាដៃគូមេគង្គ-អូស្ត្រាលី (Mekong-Australia Partnership), មជ្ឈមណ្ឌលមេគង្គ-អូស្ត្រាលីសម្រាប់ទឹក និង ប្រព័ន្ធធារាសាស្ត្រ (Mekong-Australia Centre for Water and Irrigation), ភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (P4I) និង ការវិនិយោគកសិ-ចំណីអាហារ ។ ទន្ទឹមនេះ **ឯកឧត្តមអគ្គរាជទូត** ក៏បានលើកឡើងនូវសំណើផ្តល់គាំទ្រដល់កម្ពុជាលើកិច្ចការមួយចំនួនទៀត ដូចជា៖ ការសិក្សាបុរេសមិទ្ធិក្នុងការបង្កើតសួនកសិ-ឧស្សាហកម្ម, កម្មវិធីពន្លកចំណេះ និង ការគាំទ្រដល់កម្ពុជាក្នុងការធ្វើប្រធាននៃកិច្ចប្រជុំកំពូលអាស៊ាននាពេលខាងមុខ ។ បន្ថែមពីនេះ **ឯកឧត្តមអគ្គរាជទូត** ក៏បានជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** អំពីកម្មវិធីអភិវឌ្ឍន៍ក្នុងរយៈពេល ៥ ឆ្នាំបន្ទាប់ ដែលមានថវិកាគាំទ្រប្រមាណ ៩០ លានដុល្លារអូស្ត្រាលី និង អាទិភាពសំខាន់ៗ ដែលនឹងផ្តោតសម្រាប់កម្មវិធីជំហានបន្ទាប់នេះ ។

ឆ្លើយតបទៅនឹងការលើកឡើងរបស់ **ឯកឧត្តមអគ្គរាជទូត**, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានធ្វើការវាយតម្លៃខ្ពស់ និង ថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលីដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុ និង ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាពខ្ពស់ កន្លងមក ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសំដែងនូវសេចក្តីរីករាយ និង ការគាំទ្រចំពោះសំណើបន្តផ្តល់ជំនួយហិរញ្ញវត្ថុ និង បច្ចេកទេសបន្ថែមដល់កម្ពុជា និង កម្មវិធីអភិវឌ្ឍន៍ក្នុងជំហានបន្ទាប់របស់រដ្ឋាភិបាលអូស្ត្រាលី ផងដែរ ។ ជាមួយគ្នានេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ថា អាទិភាពចំពោះមុខរបស់រដ្ឋាភិបាល គឺប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ និង ការកសាងសមត្ថភាពកម្ពុជា ដើម្បីអាចរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងរយៈពេលមធ្យម និង វែង ហើយអំឡុងពេលនេះ រាជរដ្ឋាភិបាល

កំពុងរៀបចំផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដោយផ្តោតលើគោលការណ៍គន្លឹះចំនួនបីគឺ **ការងើបឡើងវិញ កំណែទម្រង់ និង ភាពធន់** (៣Rs) ដែលផ្តោតលើការគាំទ្រវិស័យអាទិភាពជាច្រើន ជាពិសេសវិស័យដែលរងផលប៉ះពាល់ខ្លាំងដោយវិបត្តិជំងឺកូវីដ-១៩។ ក្នុងន័យនេះ ជំនួយហិរញ្ញវត្ថុ និង បច្ចេកទេសរបស់រដ្ឋាភិបាលអូស្ត្រាលី គឺមានលក្ខណៈស្របគ្នាទៅនឹងអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលនឹងរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងអនុវត្តផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានផ្តល់យោបល់ជូន **ឯកឧត្តមអគ្គរាជទូត** ធ្វើការពិភាក្សាបន្ថែមជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍នានា ដើម្បីធ្វើយ៉ាងណាឱ្យគម្រោងអភិវឌ្ឍន៍ទាំងនោះមានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និង មានភាពប្រទាក់ក្រឡាគ្នា ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** ក៏ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលអូស្ត្រាលី តែងតែយកចិត្តទុកដាក់ និង ផ្តល់នូវកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដល់កម្ពុជា លើស្ទើរគ្រប់វិស័យ និង ចំទិសដៅ និង សូមជូនពរ **ឯកឧត្តម** PABLO KANG ឱ្យទទួលបាននូវជោគជ័យជាបន្តបន្ទាប់ទៀត សម្រាប់ការបំពេញភារកិច្ចនៅកម្ពុជា និង បានប្រកាសឱ្យមានការចុះហត្ថលេខាផ្លូវការលើអនុស្សារណៈនៃការយោគយល់គ្នាលើគម្រោងនៃការសិក្សាបុរេសមិទ្ធិនៃការបង្កើតសួនកសិ-ឧស្សាហកម្ម រវាងតំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង តំណាងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា ។

៙៙៙✵៚៚៚#

#